ភាគទី១

## វគ្គ បន្ទប់គ្មានពន្លឺ

មនុស្សយើងតែងតែប្រឹងប្រើត្រចៀកផ្ទៀងស្ដាប់ខ្លាំងជាងមុនទ្វេដង នៅពេលដែលភ្នែកមិនអាចប្រើការបាន។

បន្ទប់នេះងងឹតពេកហើយ។

ចំណែកសេចក្ដីសង្ស័យ និងការភ័យខ្លាចកើនឡើងជាលំដាប់។

«ខ្ញុំសួរថាអ្នកណា?»

បេះដូងនាង លោតញាប់កញ្ជ្រោល ធ្វើឲ្យសំឡេងនាងដែលលាន់ចេញមក ញាប់ញ័រស្ទើរបញ្ចប់ឃ្លាសំណួរមិនចង់បានទាល់តែសោះ។

នារីនេះ ជាកុលធីតានៃគ្រួសារមានអំណាច។

នាងជាមនុស្សមិនដែលខ្លាចអ្នកណាតាំងពីដើមរៀងមក ព្រោះថាឪពុកនាងតែងតែជាវីរបុរសដែលនៅពីក្រោយនាង មិនថានាងធ្វើបាបអ្នកណា ឬបំពានលើអ្នកណា នាងតែងតែជាភាគីខាង«ឈ្នះ»។

ប៉ុន្តែនៅពេលនេះ អង្គរក្សដែរហ័សទាំងឡាយ បាត់ស្រមោល មិនឮសូម្បីតែស្នូរដង្ហើមមួយនៅក្បែរៗនេះ។

«បន្ទប់ងងឹតប៉ុនណា នៅយូរៗទៅគង់តែ អាចសម្គាល់ ឃើញទ្រង់ទ្រាយខ្លះ ចុះម៉េចក៏កន្លែងនរកនេះ នៅយូរទៅ កាន់តែផ្សារភ្នែក សម្គាល់ទិសតំបន់មិនឃើញ?»

នាងគិតទាំងក្ដៅក្រហល់ក្រហាយក្នុងអារម្មណ៍។

ទោះបីជាយ៉ាងណា រឿងរ៉ាវនៃពពួកព្រាយបិសាចដែលតែងតែមានអំណាចលើការគិតរបស់នារីទាំងឡាយ នៅតែពុំមែនជាប្រធានបទសម្រាប់នាងគិតក្នុងពេលនេះឡើយ។ អ្នកដែលនៅពីក្រោយការចាប់បង្ខាំងនេះ កំពុងធ្វើឲ្យចិត្តនាងផ្ទុះទោសៈ។

នារីអភិជនស្រែកតាមភ្លើងចិត្តៈ

«កុំឲ្យយើងដឹង ថាឯងកំពុងយកយើងមកលេងសើចណ៎ា!»

ធម្មតាកំហឹងរបស់នាងអាចធ្វើឲ្យមេឃក្រឡាប់ចាក់ ប៉ុន្តែភាពស្ងប់ស្ងាត់ឮតែសំឡេងខ្លួនឯងលាន់ខ្ទរមកវិញក្នុងពេលនេះ ហាក់បីដូចជារបៀបឌីដងដ៏មានប្រសិទ្ធភាពមួយ នាំឲ្យបេះដូងនាងខឹងសឹងស្ទុះណែន។

ដៃនារីរាវរកជញ្ជាំង ដើម្បីផ្ទង់សន្និដ្ឋានបរិស្ថានគ្រប់យ៉ាងជុំវិញខ្លួន។

ទីបំផុតនាងប៉ះវាហើយ។

«គគ្រើម? ក្រាស់ តាន់??? ជញ្ជាំងភ្នំ?»

នារីនេះគិតក្នុងអារម្មណ៍សម្ងាត់ផង ប្រឹងផងរំសៀកខ្លួនជុំវិញជញ្ជាំងសម្គាល់ស្ថានភាពបន្តទៀត ក្រែងលោអាចប្រទះឃើញមាត់ទ្វារ និងចំណុចខ្សោយណាផ្សេង។

ដៃជើងមិនមានចំណង ក៏ប៉ុន្តែនៅតែមិនស្រួលប៉ុន្មានក្នុងការរំកិលធ្វើចលនាទេ ជាមួយសំពត់រ៉ូបរឹបរឹង ម៉ូដែលច្នៃឡើងដោយម៉ាកកំពូលរបស់ពិភពលោកដ៏មានតម្លៃ។

«បើយើងលើកលែងឲ្យឯង យើងមិនមែនពិនណាទេ ចាំទុកអាមនុស្សព្រៃ!»

នាងនិយាយម៉ាត់ៗទាំងខាំមាត់។

គ្មានចម្លើយ គ្មានតម្រុយ គ្មានសញ្ញាថាមានគេណាម្នាក់ កំពុងនៅក្បែរនេះកំដរភ្នក់ភ្លើងកំហឹងរបស់នាងទេ។

ស្រីក្មេងស្រែកបន្ថែម៖

«អ្នកណានៅក្បែរនេះ? មានអ្នកណានៅទេ? ឮខ្ញុំហៅទេ! ជួយផង!»

ប៉ុន្តែមាត់ទ្វានៅឯណា? តើនៅឯណាទៅច្រកចេញនោះ? ហេតុអីបានជាគ្មានតម្រុយថាស្ថានការណ៍អាចនឹងធូរស្រាលជាងនេះ???

ស្រីជាប់ក្នុងទីបង្ខាំង សួរខ្លួនឯងស្ងាត់ៗ៖

«បរិវេណនេះប្រាកដជានៅឆ្ងាយពីត្រចៀកអ្នកផងមែនទេដឹង បានជាមនុស្សចោលម្សៀតអស់នោះហ៊ានចំហមាត់យើង ហើយមិនមានចំណង?»

នាងនឹកឃើញដល់មនុស្សម្នាក់ ដែលមួយជីវិតនេះមិនអនុញ្ញាតឲ្យអ្នកណាធ្វើឲ្យនាងពិបាកឡើយ មិនដឹងថាពេលនេះគាត់នៅឯណា?

ទឹកភ្នែកស្រីអ្នកមានរមៀលធ្លាក់ ... ជាមួយវាចាទ្រហោស្ងាត់ៗក្នុងបេះដូង៖

«ប៉ា! ជួយកូនផង! ប៉ានៅឯណា?»

……………………………………………

**វគ្គ កូនប៉ូលិស**

«សូមគោរពទាន!»

ស្នងការដ្ឋានប៉ូលិស សម្បូរការងារជានិច្ច។ អ្នកល្មើសនៅតែចេញចូល ហើយអ្នករងគ្រោះជាច្រើនកំពុងធ្វើរបាយការណ៍ទៅតាមភាពជាក់ស្ដែងដែលគេបានជួប។

គ្រប់យ៉ាងដែលឃើញនៅទីនេះ គឺជាទម្លាប់សម្រាប់កូនប៉ូលិសទាំងឡាយ ប៉ុន្តែរឿងចម្លែកថ្ងៃនេះគឺកូនប៉ូលិសម្នាក់ត្រូវបានមេធំហៅជួបជាលើកដំបូង។

«ជាតិ ចិត្រា ទៅបន្ទប់ប្រជុំជាន់ទីមួយទៅ! មេរកឯង!»

វរសេនីយ៍ត្រី ជាតិ ចិត្រា ផ្លាស់មកស្នងការដ្ឋាន២ខែហើយ ប៉ុន្តែនេះជាថ្ងៃដំបូងដែលនាយត្រូវបានហៅរកដោយ «លោកនាយ»។

«បាទបង!»

ជាមួយការឆ្លើយតប រហ័សរហួនឡើងទៅកាន់បន្ទប់លោកស្នងការតាមចលនាលោតប្រញាប់ប្រញាល់នៃបេះដូង។

អ្នកនាំពាក្យមុននេះឆ្លៀតស៊កឲ្យបន្ថែម៖

«កុំបាច់ស្លេក! ជួនកាលមេ គាត់មិនកាចដូចដែលពួកកូនប៉ូលិសធ្លាប់គិតទេអ្ហ៎! គាត់ហៅទៅឲ្យលុយចាយផងក៏មិនដឹង!»

ចិត្រាញញឹម ហើយបន្តដំណើរ។ ចិត្តនាយមិនមែនភ័យបារម្ភទាំងស្រុងទេ ព្រោះភាគរយច្រើនគឺរំភើប។ កូនប៉ូលិសណាមិនចង់ជួបមេ? ហើយជាមេកោយល្បីម្នាក់ កុំថាគាត់ឲ្យលាភសក្ការសូម្បីតែហៅមកស្តីបន្ទោស ក៏មិនចេះអន់ចិត្តអ្វីដែរ។

គេឈប់ជើងនៅនឹងមុខទ្វារបន្ទប់ហើយងើយទៅសម្លឹងស្លាក«ស្នងការ» ដែលនៅខ្ពស់ផុតក្បាល។ ដង្ហើមដកវែងៗបីដង មុនពេលវរសេនីយ៍ត្រីគោះទ្វារឲ្យសញ្ញាហើយរង់ចាំ...

«ចូល!»

ស្នងការRoyជាប៉ូលិសដ៏ល្បីឈ្មោះ។ មិនមែនបទពិសោធន៍ផ្នែកបង្ក្រាបឧក្រិដ្ឋកម្មទេ ព្រោះគេទើបនឹងមានវ័យ៣២ឆ្នាំ ប៉ុន្តែគេគឺជានិស្សិត Criminal Justice/Police Science ដែលមានពិន្ទុនិក្ខេបបទលេខមួយមកពីចក្រភពអង់គ្លេស។

គេលើកចិញ្ចើម ព្រោះសំឡេងមនុស្សវ័យចំណាស់នេះ ពុំមែនជារបស់លោកស្នងការ Roy ដាច់ខាត។

ស្នងការ Roy ដែលជាកូនប្រុសទោលនៃគ្រួសារមានឋានៈតួនាទីក្នុងសង្គមជាន់ខ្ពស់ខ្មែរ ឧស្សាហ៍បង្ហាញខ្លួនលើកញ្ចក់ទូរទស្សន៍ញឹកញាប់ រឿងកូនចៅអាច ស្តាប់ច្រឡំ?

វរសេនីយ៍ត្រីរុញទ្វារចូល។ មនុស្សបីបួននាក់កំពុងអង្គុយជុំវិញតុប្រជុំ ហើយបរិវេណនេះងងឹតប្រហែលជាកំពុងបញ្ចាំង Slide។ ទោះយ៉ាងណា នាយលេបទឹកមាត់ក្អឹកពេលឃើញបុរសមាឌក្រអាញដែលអង្គុយទីតាំងកៀកនឹងទ្វារជាងគេ។

បុរសនេះបានទាក់ចិត្តវរសេនីយ៍ត្រី ឲ្យភ្លេចគិតពីលោកនាយ Roy ដែលទើបស្ពាយសញ្ញាប័ត្រមកពីអង់គ្លេស។ មើលពីចំហៀងទៅ គាត់កំពុងស្ថិតក្នុងការសង្ស័យសមាសភាព ហើយពេលងាកមកគឺលទ្ធផលពិត១០០ភាគរយ ជាឧត្តមសេនីយ៍ឯក ឱត សាម៉ុន មេប៉ូលិសដែលល្បីឈ្មោះផ្នែកព្រហ្មទណ្ឌ កក្រើកញាក់សាច់សម្រាប់បណ្តាជនពាលផងទាំងពួងក្នុងប្រទេសនេះ។

«សូមគោរពទាន!»

វរសេនីយ៍ត្រី ពោលរហ័សបន្ទាន់ទាំងអោនគំនាប់តាមទម្លាប់របស់កងកម្លាំងប៉ូលិសជាតិ។

ជំនួសឲ្យការឆ្លើយតប លោកផ្កាយបីលើកដៃស្ដាំជាសញ្ញាឲ្យនាយអង្គុយចុះ ព្រោះរាងកាយគាត់មិនចំណាយងាកមកយូរ ដោយភ្នែកងាកត្រឡប់ផ្ដោតលើបទបង្ហាញ។

នៅកណ្ដាលផ្ទៃបន្ទប់ ដែលមានមនុស្សមិនលើសពី៥នាក់នេះ លោកឧត្ដមសេនីយ៍ឯក គឺជាតួអង្គតែមួយគត់ ដែលប៉ូលិសក្មេងយើងតាមសម្គាល់ដោយរំភើបក្នុងពេលនេះ។

«គាត់គឺជាឧត្ដមសេនីយ៍ឯក ឱត សាម៉ុន ដែលល្បីឈ្មោះជា Idol របស់កូនប៉ូលិសទាំងឡាយ!»

វរសេនីយ៍ត្រីលួចគិតដោយសោមនស្ស ញាប់ញ័រហើយអង្គុយចុះយឺតៗ។

ការបានរួមប្រតិបត្តិការ ដោះស្រាយសំណុំរឿងជាមួយគាត់ ពិតជាបំណងប្រាថ្នាសម្រាប់កូនប៉ូលិសស្ទើរបទពិសោធន៍ទាំងឡាយនៅភ្នំពេញ។

សម្រាប់នាយជាតិ ចិត្រានេះវិញ នាយយល់ថា សក្ដិបួនលើស្មាខ្លួន នៅតែជាឋានានុក្រមដ៏តូចកំប៉ិចមួយប៉ុណ្ណោះក្នុងចំណោមបុគ្គលទាំងឡាយដែលមានមុខនៅទីនេះ។

នាយរវើភ្នែកសម្លឹងពួកគេម្ដងម្នាក់ ហើយបញ្ចប់ទៅចំរូបរាងមនុស្សស្រីលើជញ្ជាំងដែលស្ថិតក្នុងបទបង្ហាញ។ នាងពិតជាសិចស៊ី ខ្ពង់ខ្ពស់ ហើយស្អាតបះសក់ តែវរសេនីយ៍ត្រី រកនឹកមិនឃើញថាជាតារាឈ្មោះអ្វីសោះ។

ឧត្ដមសេនីយ៍ឯកសាម៉ុនវាចាបន្ថែម ជាមួយសំឡេងក្រអួនខ្ទរបន្ទប់របស់លោក៖

«វរសេនីយ៍ត្រីជាតិ ចិត្រា!?»

«បាទទាន!»

នាយក្រោកឈរត្រង់ភ្លឹងសាជាថ្មី ពេលឮបុរសនេះហៅខ្លួនទាំងឈ្មោះទាំងត្រកូល និងឋានន្តរសក្ដិ។

«ពិនណាជាកូនស្រីតែមួយគត់របស់ប្រធានសហពន្ធហិរញ្ញវត្ថុ Ocean Ac នាងបាត់ខ្លួន១១ម៉ោងហើយ! ពាក្យបណ្ដឹងបានមកដល់មុននេះ២ម៉ោង! គ្រួសារ លោក មឿន ពិន សង្ស័យថាកូនស្រីកំពុងត្រូវបានចាប់ជំរិតនៅកន្លែងណាមួយក្នុងស្រុកខ្មែរ!»

ជាតិ ចិត្រាបែរយ៉ាងរហ័សមករកមនុស្សស្រីលើ Slide វិញ។

គេទើបតែនឹកឃើញថា នាងជាធីតាត្រកូលអភិជនដែលមានក្រុមហ៊ុនធំៗក្នុងដៃ ហើយមានមុខជានិច្ចលើក្របទស្សនាវដ្ដី ពួកអ្នកពាណិជ្ជករដែលគេឡូកឡាយថា «បុគ្គលជោគជ័យ» ព្រោះតែមានលុយច្រើន។

ម្ដងណោះ លោកនាយ Roy បញ្ជោញវាចាវិញម្ដង៖

«អ្នកដែលបានឃើញ ពិនណា ក្រោយគេគឺលេខារបស់នាងឈ្មោះដាវីដ! សាក្សីនិយាយថា នាងពិនណាចេញពីផ្ទះជាមួយសម្លៀកបំពាក់វែងរបៀបពិធីសមោសរ គ្រឿងអលង្ការជាច្រើនសែនដុល្លារ ហើយមានអង្គរក្ស៤នាក់តាមពីក្រោយ! ពេលនេះពួកអ្នកការពាររួមទាំងតៃកុងឡាននាង ផងក៏ទាក់ទងមិនបានដូចគ្នា!»

សំឡេងឧត្ដមសេនីយ៍ Roy ដែលពោលឡើងស្រាលៗ តាមបែបបទមនុស្សត្រកូលខ្ពស់របស់គាត់ ផ្ទុយទៅនឹងចរិតមេប៉ូលិសភាគច្រើនដែលប្រើសំឡេងធំគ្រលរ។

ពិតជាគួរឲ្យទាក់ចិត្តពេកហើយ សំណុំរឿងមួយនេះ។

តើវាជាការប្លន់ទ្រព្យសម្បត្តិ ឬមួយជាអ្វីផ្សេង?

ក្រុមអ្នកដៃដល់ប្រហែលជាបានឃ្លាំមើលនារីនេះយូរណាស់មកហើយ ព្រមទាំងមានផែនការល្អិតល្អន់មិនលែង ពុំនោះគេធ្វើម៉េចអាចឆីបានទាំងកងការពារ ទាំងម្ចាស់?

វរសេនីយ៍ចិត្រាលបផ្អៀតគិតរហ័សរហួនតាមទម្លាប់អ្នកហ្វឹកហាត់នៅប៉ូលិស ប៉ុន្ដែពេលក្រឡេកភ្នែកងាកទៅខាងនោះគេស្គាល់ច្បាស់ លោកឧត្ដមសេនីយ៍ជា មេត្តារិទ្ធ ប្រធានផ្នែកចារកម្ម និងម្នាងទៀត ឧត្ដមសេនីយ៍ ឌុក សេណាកា ប្រធាននាយកដ្ឋានបច្ចេកវិទ្យា ដែលទើបនឹងត្រឡប់មកពីសិក្សាបញ្ចប់ថ្នាក់បណ្ឌិតនៅអាល្លឺម៉ង់។

អូហូៗៗៗ!!!

តើករណីបាត់ខ្លួននេះ ស៊ីជម្រៅកម្រិតណាទៅបានជាឧត្ដមសេនីយ៍ល្បីៗមកជុំគ្នាអស់បែបនេះ?

ការគិតនេះ ពិតជាគួរឲ្យចាប់អារម្មណ៍ណាស់ សម្រាប់កូនប៉ូលិសសក្តិតូចជាងគេ។

«ខ្ញុំយល់ថា គ្រប់យ៉ាងមិនទាក់ទងនិងទ្រព្យសម្បត្តិ!»

សំឡេងឧត្តមសេនីយ៍ ឱុក សេណាកា។

បុរសនេះជាជំនាញដៃឆើតខាងបណ្ដាញ Internet និងមានបទពិសោធន៍ច្រើនលើកមក ហើយក្នុងកិច្ចសហប្រតិបត្តិការជាមួយពួកInterpol ។

សម្ដីប៉ុន្មានម៉ាត់ខ្លីៗរបស់គាត់ ទំនងជាបង្ហាញថាសំណល់ដែលរកឃើញនៅនឹងបណ្ដាញទំនាក់ទំនងនានារបស់នារីបាត់ខ្លួន បានបង្ហាញចេញមកពីមូលហេតុផ្សេងនៅក្រោយរឿងនេះ។

បរិយាកាសហាក់បីដូចជារំភើបឡើងដល់កម្រិតកំពូលហើយ។ គ្រប់យ៉ាងប្រៀបបីដូចជាចំណងជើងរឿងចិនកាលឆ្នាំកៅប្លាយ «ខ្លាំងប៉ះខ្លាំង» អ៊ីចឹងមែន។

ចុះខ្លួន? មានត្រូវហៅមកនេះ មាននាទីជាអ្វីដែរក្នុងភាពយន្តជីវិតពិតនេះ?

បេះដូងលោកសក្តិបួន លោតក្តុកក្តាក់ ហើយអន្ទះសារង់ចាំត្រងត្រាប់ព័ត៌មានបន្ត។

ប៉ុន្តែសម្តីលោកឧត្តមសេនីយ៍ Roy លាន់មកកាត់ផ្ដាច់ចង្វាក់បេះដូងនាយ៖

«ខ្ញុំហៅលោកមក ដើម្បីប្រគល់ភារកិច្ចតួនាទីពិសេស!»

សាជាថ្មីនាយសក្តិបួនឈរត្រង់ខ្លួន ហើយគោរពត្រសងជាមួយពាក្យពីម៉ាត់៖

«បាទទាន!»

មានពេលណាត្រេកអរស្មើពេលនេះ?

បានរួមការងារជាមួយប៉ូលិសល្បីៗគ្រាក់ៗ កូនប៉ូលិសណាមិនស្ម័គ្រស្លាប់?

ប៉ុន្តែ...Roy ឈប់និយាយហើយគេស៊ីញ៉ូឱ្យជាតិចិត្រាងាកទៅកាន់ឧត្តមសេនីយ៍ផ្នែកព្រហ្មទណ្ឌ ដូច្នេះបុរសចំណាស់ដ៏មានឥទ្ធិពលចាប់ផ្ដើមស្រដីមួយៗ៖

«កូនស្រីខ្ញុំ អមរាជាអាយុ១៨ឆ្នាំ ដំណាលនាងពិនណាដែរ! ខ្ញុំប្រគល់សុវត្ថិភាពនាងទៅក្នុងការប្រុងជើងការរបស់លោក! លោកត្រូវបំពេញភារកិច្ចនេះ ឲ្យបាន១០០ភាគរយ!?»

មោទនភាពជាកូនប្រុសសក្តិពេញស្មា ស្រាប់តែត្រូវធ្លាក់របូតខ្ទាកពីប្រអប់ទ្រូងភ្លាមៗ ហើយរលាយបង់ខ្យាកៗ លឿនជាងអំបិលត្រូវទឹកទៅទៀត។

គេងើបមុខ ប្រទះឃើញក្រសៃភ្នែកមាក់ងាយសម្ងាត់មួយពីបុរស Roy ដែលខ្លួនធ្លាប់គោរព ចង់ស្គាល់ចង់យកជាគំរូ។

ស្នងការដែលជាមេកោយផ្ទាល់ហាបន្ថែមមកលើសង្វាក់បេះដូងកូនប៉ូលិស៖

«ខ្ញុំអនុញ្ញាតតាមសំណូមពររបស់លោកឧត្តមសេនីយ៍ ឱ្យចិត្រាឯងដូរទៅធ្វើការនៅផ្ទះគាត់មួយរយៈ!»

ស្នាមញញឹមនៃចាស់ៗទាំងឡាយនៅទីនេះ ដូចជាចង់បញ្ឈឺនាយភ្លាមៗព្រមៗគ្នាថា «មើលខ្លួនផង!មុនចង់តោងកាលីបចូលសំណុំរឿងកម្រិត A?»

## វគ្គ កូនស្រីលោកផ្កាយ

«ឲ្យកូនយកអង្គរក្សដើរតាម អូយគេសើចស្លាប់ហើយម៉ាក់សម័យណោះទៅហើយ!»

អ្នកនាងទោលអមរាជាជាស្តេចក្រាញ់ដ៏ Cute បំផុតក្នុងភូមិគ្រឹះរបស់ឧត្តមសេនីយ៍ ឱត សាម៉ុន។ នាងជាស្រីតូចមានសម្បុរស្រអែមរាងរាវ ហើយមានកែវភ្នែកមុតៗដូចជាកូនឥណ្ឌា។ ទោះនាងមើលទៅមានកាយសម្បទាដូចជានារីខ្មែរសលើសពីសម័យបុរាណ ប៉ុន្តែនាងពិតជាមានលក្ខណៈង៉ិកង៉ក់ជាកូនទោលដែលមិនព្រមធំ។

នាងលូកឱបម្តាយដែលកំពុងដកដង្ហើមធំ។ នាងដឹងថា អង្គរក្សប្រុសកំលោះ ចូលមកនៅក្បែរកាយ ក៏ពុំមែនជាអ្វីដែលអ្នកម្តាយគ្រប់រូបចង់បាននោះដែរ ដូច្នេះគេនៅតែមានសម្រាប់ការលួងលោម សុំអន្តរាគមន៍។

«អ្នកម៉ាក់ជួយគិតដាផងមើល៍! ដាដែលទៅណាផ្តេសផ្តាស ដាមានដែលទៅដើរលេងសើចអីដូចកូនអ្នកមានអស់នោះ ប៉ាដាជាប៉ូលិសធំ មានអ្នកណាហ៊ានទៅ???»

ជំទាវរ៉ាស៊ីងក់ក្បាលហើយបន្ទរស្រាលៗ បន្តពីកូនស្រីសំណព្វ៖

«ម៉េចក៏ប៉ា មិនរកអង្គរក្សស្រីហ្នកូន?»

អមរាជាបូញមាត់៖

«ឲ្យតែឈ្មោះថាអង្គរក្ស គួរឲ្យធុញតែទាំងអស់ហ្នឹង! អង្គរក្សអី ពួកឆ្អឹងទទឹងកមិនថា!»

ជំទាវដកដង្ហើមវែងហើយលួងលោមៈ

«កុំប្រញាប់ថាពេកកូន! លោកប៉ាតែងគិតអ្វីល្អិតល្អន់ណាស់ ម៉េចៗចាំលោកប៉ាមកដល់សិន!»

ស្នូររថយន្តលាន់នៅជាន់ខាងក្រោម។ ទោះប្រភេទរថយន្តទំនើប មានសំឡេងតិចតួចកម្រិតណា ស្ត្រីរូបនេះនៅតែចំណាំដឹងថាជាស្វាមីរបស់ខ្លួនមិនរំលង។ មុនពេលគាត់រលះរលាំងចេញទៅ កូនស្រីឆ្លៀតលើកហ្វេសប៊ុកបង្ហាញ ហើយរអ៊ូះ

«អ្នកម៉ាក់មើលចុះ! មុខអ៊ីចឹងហើយឈ្មោះអ៊ីចឹង?»

គាត់ពិនិត្យតាមការបង្ហាញរបស់កូនស្រី។ ពិនិត្យឃើញកាលណាចងចិញ្ចើមបង្ហាញអារម្មណ៍មិនពេញចិត្តដូចគ្នា។

«កូនបាន Profile ក្មេងនេះពីណាមក?»

«កូន Search! និយាយរួម គ្មានឃើញអីគួរឲ្យទុកចិត្ត ថានឹងត្រូវយកដើរតាមនោះទេ! កោតលោកប៉ាដល់ហើយ!»

ជំទាវរ៉ាស៊ីងក់ក្បាលទទួលព្រមតាមគំនិតនាង។ លោកបញ្ជាក់មុនពេលក្រោកចេញៈ

«បានហើយ! ចាំម្ដាយទៅនិយាយហ្នឹងប៉ាឲ្យ!»

បានដូចចិត្ត នារីតូចញញឹមបញ្ចេញថ្ពាល់ខួច។

«ចាសៗៗៗ! អរគុណណាស់អ្នកម៉ាក់!»

នាងឱបថើបស្ត្រីជាម្ដាយតាមទម្លាប់មុនពេលលោកក្រោកចេញទៅទទួលប្រតិបត្តិស្វាមី។

«ឮថាបងឲ្យអង្គរក្សមកតាមកូនដា?»

លោកឧត្តមសេនីយ៍ឮតែសម្ដីភរិយាមួយឃ្លានេះ ជ្រាបជាស្រេចថាមានរឿងអ្វីកំពុងកើតឡើងទៅហើយ។ លោកហុចអាវក្រៅទៅភរិយាហើយដើរតម្រង់តុបាយ។

«បងប្រជុំ៧ម៉ោងហើយ បងឃ្លានណាស់!»

គាត់និយាយទាំងទាញកៅអីអង្គុយនឹងលើកកែវភេសជ្ជៈមកក្រេប។

នៅលើជណ្ដើរលោកក្រឡេកទៅឃើញជាយសំពត់កូនសំណព្វ បុរសជាឪពុកក៏ដឹងស្រេចទៅ ហើយថានាងកំពុងត្រូវការអ្វី ដូច្នេះហើយលោកក៏ប្រញាប់បញ្ចប់រឿង៖

«ប្រាប់កូនដាទៅ! រឿងអង្គរក្សឈប់ជជែក! ស្អែកនេះគេមកធ្វើការហើយ! គេធ្វើម៉េចក៏ដោយតាមវិធីរបស់គេទៅ ខ្ញុំមិនរវល់ឲ្យតែកូនដាមានសុវត្ថិភាពរៀនសូត្រស្រួលបួល!»

ម្ដាយនាងជួសបាយជូនស្វាមីផង លបលួចសម្គាល់ទឹកមុខម៉ឺងម៉ាត់របស់គាត់ផង។

រង់ចាំទាល់តែបុរសនេះបានអាហារដល់ក្រពះដែលកំពុងតឿននោះ មួយម៉ាត់ពីរហើយទើបជំទាវហ៊ានចូលប្រធានបទ៖

«លោកប្ដីខ្ញុំទុកចិត្តគេពេកដឹង? ត្រឹមកូនប៉ូលិសសក្ដិបួន ហេតុអីឲ្យមកនៅក្បែរកូនស្រីខ្លួន ២៤ម៉ោងកើត? មានតែកុងហឿនហើយ មិនបាច់ថែមអង្គរក្សទេ បើថាមិនទុកចិត្តចាំអូនទៅជាមួយតែកុងទទួលកូនដារាល់ពេល!»

ឧត្ដមសេនីយ៍បង្ហើយបាយពីស្លាបព្រាររួចទំពាម៉ត់មុនពេលជូតមាត់តប៖

«សក្ដិបួនជាកូនប៉ូលិស? ចុះកាលលោកជំទាវរ៉ាស៊ីព្រមស្រលាញ់ខ្ញុំ ខ្ញុំទើបតែសក្ដិ២ មិនអំបាតថៃប៉ូលិសទៅហើយ?»

លោកជំទាវញញឹមស្រស់ ពេលត្រូវស្វាមីរំលឹករឿងដើម។ មុនពេលវាចាលោកឆ្លៀតថែមបាយជូនប្ដី៖

«មនុស្សខុសគ្នា! លោកឧត្ដមសេនីយ៍យកខ្លួនទៅប្រដូចជាមួយក្មេងនោះ? លោកជាអ្នកណាហើយគេជាអ្នកណា? លោកជាមនុស្សមានបារមី ប្រុងតែនឹងធំ! ពេលជួបឃើញភ្លាម ទោះសក្ដិពីរក៏មានអារម្មណ៍ដឹងថាផ្កាយពីរក៏មិនស្មើលោកផង!»

លោកផ្កាយឱនសំងំបរិភោគរក្សាទឹកមុខស្មើ ប៉ុន្ដែលោកជំទាវដឹងថាបុរសនេះកំពុងរំភើបនឹងពាក្យសរសើររបស់ភរិយា។

ដៃម្ខាងលោកចុចទូរសព្ទបង្ហាញព័ត៌មាននៅលើ៣០ដេលីឲ្យប្រពន្ធបានឮ។ សំឡេងអ្នកអានព័ត៌មានឌូគូលាន់មកក្រអួន «រហូតមកដល់ពេលនេះ គ្រួសារអ្នកនាងពិនណាចាត់ទុកថានេះជាករណីចាប់ពង្រត់ដែលទាមទារឲ្យសមត្ថកិច្ចខ្មែរបំបែកឲ្យខាងតែបាន! គួររំលឹកថា ជនរងគ្រោះជានារីអភិជនទី៣ហើយ ដែលត្រូវបានបាត់ខ្លួនក្នុងរវាងពេល៩៦ម៉ោង គឺថ្ងៃបន្តបន្ទាប់គ្នា! សមាសភាពពួកគេសុទ្ធតែមានប្រភពមកពីគ្រួសារមានប្រាក់មានកិត្តិយស ប្រការនេះធ្វើឲ្យគ្រួសារអភិជនខ្មែរដែលមានកូនស្រីៗក្នុងបន្ទុក ស្ថិតក្នុងសភាពប្រុងប្រយ័ត្នតឹងតែង!»

ឃើញលោកជំទាវ ចំហមាត់ព្រួយភ័យលោកឧត្តមសេនីយ៍ក្រេបទឹកមួយក្អឹកហើយនិយាយពន្យល់៖

«បងរកមនុស្សមកឲ្យលោកជំទាវធូរចិត្ត ចំពេលចំកាលល្អហើយ! មិនអាចប្រហែសបានទេមួយរយៈពេលនេះ! ហើយបើចាំបាច់ បងប្រហែលអាចឲ្យអមរាជា ផ្អាកចេញពីផ្ទះមួយរយៈ!»

ពីកន្ទុយភ្នែក លោកជំទាវឃើញព្រះនាងតូចរបស់គាត់អង្គុយចុះប៉ុកលើជណ្ដើរធ្វើមុខក្រញូវ។ គាត់ងាកមកលោកប្ដី ឃើញចាប់ផ្ដើមបរិភោគបង្អែមបញ្ជាក់ថាលោកឆ្អែតបាយហើយអារម្មណ៍ក៏បានល្អប្រសើរឡើងជាងមុនដែរ។

ឆ្លៀតពេលនេះលោកជំទាវវ៉ាស៊ីបន្តប្រយោគម៉្មិកម៉្ញក់៖

«បើថារើសអង្គរក្សរើសចុះ ប៉ុន្តែក្មេងម្នាក់នេះ...?»

លោកប្ដីនិយាយកាត់៖

«គេជាក្មួយបង្កើតរបស់សេតវិទូ!»

លោកជំទាវងើបមុខមកសម្លឹងប្ដី ព្រោះឈ្មោះដែលគាត់បង្ហើបដូចជាអ្នកណាម្នាក់ដ៏មានឥទ្ធិពលក្នុងចង្កោមប៉ូលិស គ្រាន់តែនឹកមិនឃើញភ្លាមៗថាជាអ្នកណា។

«ឧត្តមសេនីយ៍ចូលនិវត្តន៍ ដែលធ្លាប់ល្បីបំបែកក្ដីស្ទូឌីយោលេខ៧ និងរឿងឃាតកម្មរបស់អ្នកស្រីកុលាបនៅសង្កាត់លេខមួយ?»

បុរសមានឋានៈឱនមកឱបស្មាភរិយាជាមួយស្នាមញញឹមនិងវាចាសរសើរ៖

«សមជាប្រពន្ធប៉ូលិសពិតៗ!»

លោកជំទាវបែរមករកស្វាមីជាមួយកែវភ្នែកឆ្ងល់ភ្លឹះៗ៖

«ចុះថា កាលពីចប់រឿងឃាតកម្មZ22 គេនោះរៀបការជាមួយមេធាវីស្រីម្នាក់ហើយ លាឈប់ពីការរាជការ???»

«មានអ្នកណាថាគេមិនបានលាឈប់?»

ប្ដីឆ្លើយធ្វើហី ហើយថយទៅអង្គុយអានព័ត៌មានក្នុងទូរសព្ទបន្ត។ ភរិយាងាកទៅរកកូនស្រីវិញ មើលប្រតិកម្មរបស់នាងឃើញថា នាងមិនខ្វល់ប៉ូលិសសេតវិទូជាអ្នកណាទេ។ ស្រីស្អាតអមរាដានៅតែក្រញូវ ដូច្នេះអ្នកម្ដាយធ្វើដៃស៊ីញ៉ូ ឲ្យនាងហុចទូរសព្ទមកឲ្យ។

អ្នកនាងតូចចុះពីបីកាំមកហុចរបស់ជូនម្ដាយទាំងដំណើររំអុកម៉ិកង៉ក់។

លោកជំទាវបានវត្ថុដែលខ្លួនចង់ផ្ចាញ់លោកប្ដីភ្លាមកាលណា ក៏យកទៅចុចបើកបង្ហាញចេញនៅនឹងមុខឧត្ដមសេនីយ៍។

លោកឱិត សាម៉ុន ងើបមុខមកមើល មុនពេលបើកភ្នែកធំៗរបៀបហួសចិត្ត។

បានដូចចិត្ត លោកជំទាវចំអកក្នុងសំឡេងស្រទន់៖

«ក្មួយពីណាមិនសំខាន់ ទោះពូគេពូកែ តែមើលចរិតក្មួយចុះ! មើលឈ្មោះដែលប្រើចុះ! គ្មានឃើញត្រង់ណាគួរឲ្យទុកចិត្តបានទេ!»

ភាគទី២

**វគ្គ លោកប៉ូលិសកំពូលhack**

«ឯងមែនទេ? ឯងទៀតហើយមែនទេអាមាន? ឯងមក hack  Account អញរកក្បាលអីឯងនៅហ្នឹង? ហើយឯងដូរឈ្មោះ Profile អញធ្វើស្អី! ឈ្មោះ Profile អញវាទើសស្អីឯង?»

ចិត្រានិយាយទាំងក្ដៅក្រហាយជាមួយមិត្តកំពូលប៉ូលិស hacker ដៃឆើត។

លោក Hacker សក្ដិបួនដូចគ្នាអង្គុយសើចរលាក់ ពេលឃើញពួកម៉ាកខឹង។

កាហ្វេពីរពែងលើកមកដល់ ជាមួយសំណួរស្រទន់នៃស្ត្រីវ័យចំណាស់៖

«ហើយក្អួយមានទៅ hack account របស់កូនចិត្របួរឈ្មោះថាម៉េចខ្លះ បានជាកូនចិត្រខឹងទាំងព្រលឹម???»

ឯកមាន បុរសសក្តិបួនវ័យក្មេងគិតពីសើចកក្អឹក មិនឆ្លើយនឹងស្ត្រីចំណាស់ដែលកំពុងអង្គុយចុះមកឃើតៗក្បែរពួកគេ រួមតុកាហ្វេជាមួយគ្នានោះ។

ម្នាក់ៗដូចកំពុងទុកឱកាសឲ្យចិត្រាឆ្លើយតបទាំងកំហឹង៖

«ម៉ាក់មើលខ្លួនឯង! វាhackលើកទី១០០ហើយ រៀនធុនៗវាhack តេស្ត១០០០ដងទៀត ក៏វាមិនខ្មេះអីដែរ!!! សំខាន់ទៅhackគេផ្សេង ខ្លាចត្រូវខៀវភ្នែក បានជាវាមកhack តែនៅហ្នឹង! លើកនេះមានធម្មតាអី ខ្ញុំកំពុងត្រូវមេប្រើឲ្យចូលធ្វើអង្គរក្ស ការងារមិនទាន់បានធ្វើ ម្ចាស់ដែលត្រូវបម្រើមិនទាន់ជួបផង វាដូរ Profile ដាក់ខ្ញុំថា កំពូលស្នេហ៍??? លោកនាយ ឱត សាម៉ុនខលមកស្តីឲ្យទាំងព្រឹក គាត់សួរចុះសួរឡើងសួរហើយសួរទៀតថា ខ្ញុំចេកមែនឬអត់? សមដែរ? អាចោរ!»

ម្តាយក្តាប់មាត់សើចចំណែកនាយឯកមាន ត្រូវមួយសំបកដបទឹកសុទ្ធគេចរឹងទៅម្ខាងហើយបន្តសើចរលាក់ធ្វើឲ្យចិត្រាមិនស្រន់សម្តី បន្តទៀតរ៉ាវៗ៖

«កំពូលស្នេហ៍អ្ហែងអី??? អ្ហែងចង់ចេកណាស់ដាក់ Profile ខ្លួនឯងទៅ? កំពូលស្នេហ៍? អារំបល់យក៏!»

ព្រោះតែចិត្រាគប់មិនឈប់ទើប ឯកមាន ឈប់សើចប្រឹងពន្យល់ហេតុផល៖

«គ្រប់យ៉ាងវាមានដើមមានចុងមានហេតុមានផល! អញឯណោះសង្ហាពេកស្រីតាមគគោកដីទ្រាំគេចមិនរួចក៏រកឯងមកធ្វើសង្សារ បើមិនដូរ Profile ឯងជាកំពូលស្នេហ៍ ធ្វើម៉េចបន្លំភ្នែកបាន?»

«ចាំអញhackវិញ អញដាក់អ្ហែងថាឃាតករចាប់ស្រីអានាង!»

«ចាំអ្ហែងរៀនចេះសិនចាំនិយាយអាចិត្រ!»

ម្ដាយសម្លឹងក្មេងទាំងពីរដែលធំឡើងមកជាមួយគ្នា ដូចមនុស្សកើតចេញពីផ្ទៃតែមួយ។ គាត់សុំទៅហើយនឹងបរិយាកាសបែបនេះ។ អ្នកស្រីបែរទៅចុចទូរទស្សន៍ទស្សនាម្ដងបន្ទប់ស្ថានការណ៍។

ករណីបាត់ខ្លួនរបស់កូនស្រីអ្នកមាននៅតែជាព័ត៌មានក្ដៅបន្តវិភាគចុះឡើងសម្រាប់អ្នកធ្វើការសឹងគ្រប់ទូរទស្សន៍។ អ្នកស្រីរបូតមាត់ទាំងបារម្ភ៖

«រឿងនេះដូចជាកាន់តែជ្រៅម៉េចមិនដឹងទេកូន! បួនថ្ងៃមនុស្សបាត់៣នាក់បន្តបន្ទាប់គ្នា?»

ឯកមានឈប់លេងសើច គេសម្លឹងអេក្រង់ហើយដៀងភ្នែកមករកប៉ូលិសជាត្លើ។

«នេះជាមូលហេតុដែលលោកនាយឱិតសាម៉ុន ត្រូវការអង្គរក្សតាមឃ្លាំងកូនស្រីគ្រប់ជំហាន!»

ឃើញចិត្រានៅពិចារណាព័ត៌មានស្លុងអារម្មណ៍ ឯកមានឌីដងគួកនសាជាថ្មី៖

«ហើយគាត់មកស៊ិយរកចំអាប៉ូលិសឈ្មោះកំពូលស្នេហ៍ហាសហា!»

ពេលនេះទោះឈ្មោះខ្លួនក្លាយជាអ្វីក៏មិនសំខាន់ចិត្តនាយសក្តិបួន កំពុងគិតអំពីសំណុំរឿងបាត់មនុស្សដ៏សែនរសើប។

«ខ្ញុំចង់ចូលរួមដោះស្រាយក្ដីនេះ!»

គេនិយាយមួយៗទៅកាន់ម្ដាយ ប៉ុន្តែអ្នកដែលតបគឺ hacker ឯកមាន៖

«ឯងយកស្អីទៅធ្វើ?»

«យើងមានប្រផ្នូលថា មានអ្វីមួយដែលយើងអាចរកឃើញតម្រុយក្នុងរឿងនេះ!»

«ស្អីទៅ?»

ឯកមានសួរឌឺ ធ្វើឲ្យជាតិចិត្រាងាកមកវិញ ហើយឌឺតប៖

«ប្រាប់ឯងបានការអី?»

«អាប៉ូលិសប្រើអារម្មណ៍!»

«មិនមែនអារម្មណ៍ទេ គឺញាណ!»

ម្តាយដកដង្ហើមធំ ហើយនិយាយកាត់មួយៗ៖

«ម៉េចមិនពិភាក្សាជាមួយពូឯងកូន?»

ចិត្រាដៀងភ្នែកសម្លឹងមិត្ត តែចិត្តគេនឹកទៅដល់ឧត្តមសេនីយ៍សេត វិទូដ៏ស្រស់សង្ហាដែលនៅតែជាវីរបុរសជានិច្ចក្នុងបេះដូងពួកប៉ូលិសជំនាន់ក្រោយ។

តាំងពីសំណុំរឿងfolderគីមីZ22បានបំបែកហើយបន្សល់នូវស្លាកស្នាមឈឺចាប់ផ្ទួនៗលើជីវិតរបស់ភីណា វិទូបានលាឈប់ពីជីវិតជាកងប៉ូលិសជាតិ។

គាត់បានសម្រេចចិត្តជួយភរិយាជាមួយក្រុមហ៊ុនសេវាផ្នែកច្បាប់របស់នាង ហើយពួកគេសឹងតែត្រូវបានអ្នកផងភ្លេច។

ទោះយ៉ាងណា ស្នាដៃឆ្នើមៗកាលពីអតីតកាលគឺជាអ្វីដែលមិនចេះសាបរលាប។ វាប្រៀបដូចភាសិតមាសរបស់ខ្មែរដែលចារទុកថា«ទូកទៅកំពង់នៅ»។ រាល់ពេលមានក្តីពិបាកៗលេចឡើង មនុស្សម្នាចាប់ផ្តើមនឹកឃើញដល់ប៉ូលិសវិទូ។ ចិត្រាឈ្ងោកមុខសម្លឹងជើងខ្លួនឯង។

ក្តីអាម៉ាស់មួយបង្ហាញចេញមកហាក់ចង់បន្ទោសខ្លួនឯងនៅមុខមនុស្សម្នាថា ខ្លួនមិនបានស្ទូម្បីមួយចម្រៀកនៃលោកមា។

ឯកមាន បន្លប់ទុក្ខសោករបស់មិត្តដោយនិយាយកំប្លែងបង្អាប់៖

«គិតច្រើនធ្វើស្អី? រំខានពូបានការអី? ការងារខ្លួនជាអង្គរក្ស ធ្វើតាមនាទីទៅ បើមិនចង់ធ្លាក់សក្តិ!ចំណែកក្តីបាត់មនុស្សឯងចង់មានញាណ១០ទៀត ក៏ពុំទាន់ដល់វេនឯងដែរអាចិត្រ!»

មិនរវល់ខឹងមិត្ត ជាតិ ចិត្រវាចាចេញនូវអ្វីមួយដែលខ្លួនកំពុងផ្ងង់ទៅរកយ៉ាងស៊ីជម្រៅ។ វាចាគេស្រាល់ៗតែម៉ឺងម៉ាត់៖

«ម៉េចក៏អញមានអារម្មណ៍ថា ករណីបាត់ខ្លួនទី៤នឹងលេចឡើងក្នុងយប់នេះ?»

ម្តាយងាកមកដោយព្រួយបារម្ភ… ចំណែកនាយឯកមានក៏ដៀងភ្នែកសម្លឹងមិត្តយឺតៗ…

**វគ្គ ជនរងគ្រោះទីបួន**

... ពន្លឺភ្លើងពិលបំភ្លឺមកតិចតួចហាក់បីដូចជាកំពុងតស៊ូនឹងភាពងងឹតស្លុបដែលគ្របដណ្ដប់ដោយរាត្រីកាល នាបណ្ដោយផ្លូវលំ គ្មានអាជ្ញាធរយកចិត្តទុកដាក់នឹងបំភ្លឺលំអ្វី។

បុរសក្មេងម្នាក់ បង្ហាញស្រមោលរបស់ខ្លួនហើយរវៀសរវៃ ត្រេចចរស្ទាត់ជំនាញបំបាំងខ្លួនទៅក្នុងស្បៃអន្ធការ។

ស្នូរទឹកលាន់ឡើងភ្លូកផ្លាក។

នេះពុំមែនជាផ្លូវទឹកទេ តែជាតំបន់ក្រុងដែលលេចលង់ក្រោយមហាព្រះភិរុណបង្អុររលំមេឃ។

សត្វល្អិតមិនឮអ្វីសូម្បីតែមួយច្រេក ...

សភាពការណ៍ស្ងាត់ពេកហើយ ខុសប្រក្រតីពេកហើយ ម្ដេចឡើយរថយន្តទំនើបមួយហ៊ានបោះពួយមកតែឯងឯកា?

សឹងមិនគួរឲ្យជឿ ដែលទំនើបតម្លៃក្បែរលានដុល្លារអាមេរិកត្រូវឈប់ង៉ក់ហាក់មិនបានព្រាងទុក។

ឡានមួយបោលវេរមកដល់ពីក្រោយ យ៉ាងតក់ក្រហល់ ហើយមនុស្សប្រុសៗបីនាក់បង្ហាញខ្លួនចេញពីក្នុងតួរថយន្ត សស្លាក់សស្លេីត។

ពួកគេមកព័ទ្ធការពារឡានទំនើបខាងមុខជាមួយនឹងពិលទូរស័ព្ទគ្រប់ដៃបន្ថែមពីលើពន្លឺហ្វាឡានភ្លឺរោល......

«ស្អីគេអ៊ីចេះ! អាណាដាក់អីលើថ្នល់អ៊ី?»

«អ្នែងបញ្ចាំងពិល អញមើលកង់បន្តិច!»

«អាតែកុង កុំចុះមកឲ្យសោះ! នៅមើលការពារអ្នកនាងពៅ!»

ស្រមោលជាច្រើនកើតភ្លែតភ្លឹបចុះឡើងនៅក្នុងវេលាកណ្ដាលរាត្រី។

អ្វីៗស្ងប់ស្ងាត់កប់បាត់ គ្មានសញ្ញា ប៉ុន្តែនៅម៉ោង៣ភ្លឺ ទូរទស្សន៍នានាបានដាស់អ្នកភ្នំពេញឲ្យក្រោកមកស្ដាប់សេចក្ដីរាយការណ៍ទាំងបុកពោះបារម្ភ។

«គ្រួសារលោកចៅក្រម មុនី តារា កំពុងស្ថិតនៅស្នងការដ្ឋានរាយការណ៍ពីបណ្ដឹងកូនស្រីពៅ មុនី សក្ដា ដែលបាត់ខ្លួនទៅរួមជាមួយតែកុងឡាន២និងអង្គរក្សបីនាក់! ប៉ូលិសកំពុងក្រពុលមុខជាមួយ និងការបាត់ខ្លួនកូនស្រីមកពីសង្គមជាន់ខ្ពស់ដែលកើតឡើងជាបន្តបន្ទាប់គ្មានរកតម្រុយមិនឃើញ! យ៉ាងណាមិញអគ្គស្នងការនគរបាលជាតិ បានចេញសេចក្ដីប្រកាសជាបន្ទាន់នៅមុននេះបន្តិច ដោយអំពាវនាវឲ្យមានកិច្ចសហការនិងយកចិត្តទុកដាក់ខ្ពស់ពីសាធារណៈជន ក្នុងការជួយដល់ប៉ូលិស ផ្ដល់ព័ត៌មាន ដែលនាំទៅដល់ការស្រាវជ្រាវបំបែកសំណុំរឿងដ៏រសើបនេះ!»

ស្នូរទូរសព្ទដាស់បុរសសក្ដិបួនឲ្យស្រវាក្រោកពីសុបិនដ៏ខ្មៅងងឹតមួយ។

ឃើញច្បាស់ថាជា សម្លាញ់អាប់ ឈ្មោះឯកមាន ជាតិ ចិត្រាបិទភ្នែកវិញមុនពេលចុចនិយាយ ៖

«ម៉ោងប៉ុន្មានហើយ?»

សំឡេងមិត្តមិនបានឆ្លើយនូវសំណួរក្រងួរនេះទេ ប៉ុន្តែគេនិយាយរឿងផ្សេងមកវិញជាបន្ទាន់៖

«ករណីទីបួនកើតឡើងមែនហើយអាចិត្រ! ម្ដងណេះ កូនលោកចៅក្រមមុនីតារាវើយ!»

ជាតិ ចិត្រាបើកភ្នែកខ្វាក។

ភាពខ្ជិលប្រអូសរលត់អស់ ជំនួសមកវិញនូវអារម្មណ៍មួយពិបាកពណ៌នា។

«កងការពារនិងតៃកុង៥នាក់ ឡានពីរគ្រឿង បាត់ទាំងអស់! ខាងស្នងការកំពុងឆែកឆេរសឹងរបើកភ្នំពេញហើយអានេះ អ្ហែងដេកកើតទៀត?»

«ពីអង្កាល់?»

គេសួរឡុលៗហើយច្រត់ដៃក្រោក។

«អ្ហែងមិនបើកទូរទស្សន៍មើល?»

ជាតិ ចិត្រាស្រវារកតេឡេទូរទស្សន៍។

«អ្ហែងមើល អាណាគេធ្វើនេះវាធ្វើគឃ្លើនហ្មងអ្វ៉ា!»

ចិត្រាចុចទូរស័ព្ទបិទទាំងមិនបានតបនឹងមិត្តសូម្បីតែមួយម៉ាត់ណា។

គេក្រោកសន្សឹមៗ ទៅពិនិត្យនារីរងគ្រោះដែលកំពុងបង្ហាញរូបថតលើអេក្រង់។

គេសម្លឹងហើយសម្លឹងទៀត កាន់តែសម្លឹងកាន់តែស្លុង។

អស់មួយខណៈនាយគ្រវាត់តែឡេទៅលើពូកហើយរត់ទៅទាញ laptop មកបើកឲ្យដំណើរការទាំងប្រញាប់ប្រញាល់។ នាយសក្តិបួនធ្វើអ្វីម្យ៉ាងទៅលើឧបករណ៍នេះយ៉ាងជក់ចិត្ត។

ចុងក្រោយនាយគ្រវីក្បាលយឺតៗ ក្នុងទឹកមុខហួសចិត្ត...

បុរសងើបមុខសម្លឹងនាឡិកាលើជញ្ជាំង... ម៉ោងទើបតែ៥ភ្លឺប៉ុណ្ណោះ គេយល់ថាវាមិនសក្តិសមទេ តែគេមិនអាចរង់ចាំទៀតបានឡើយ។ វរសេនីយ៍ត្រីលើកទូរស័ព្ទហើយបង្អង់គិតមុនពេលសម្រេចចិត្តផ្ទុងថា...

«ជម្រាបសួរទាន! នេះវរសេនីយ៍ជាតិ ចិត្រាទាន!»

«អូខេចិត្រាមានការអីឆាប់និយាយមក!»

សំឡេងឧត្តមសេនីយ៍ ឱត សាម៉ុនមិនបានបង្ហាញថា គាត់ទើបនឹងក្រោកពីដំណេកនោះទេ។ ដូច្នេះហើយចិត្រាកាន់តែមានកម្លាំងចិត្តក្នុងការសន្ទនា៖

«សូមអភ័យទោសដែលទូរសព្ទរំខានថ្មើរណេះទាន!»

«កុំនិយាយវែងឆ្ងាយ! គ្មានប៉ូលិសណាដេកលក់ទេ ពេញមួយភ្នំពេញនេះ! មានអ្វីឆាប់រាយការណ៍មកភ្លាម បើគ្មានទេឆាប់ទៅដល់ផ្ទះខ្ញុំហើយការពារកូនស្រីខ្ញុំ២៤ម៉ោងលើ២៤ម៉ោង!»

ចិត្រាដកដង្ហើមធំ ពេលឮពីតួនាទីជាអង្គរក្ស។

សរសៃឈាមជាអ្នកស៊ើបកំពុងរត់រសឹបពេញសារពាង្គកាយ ហើយករណីកក្រើកប្រទេសកំពុងនៅចំពោះមុខ នាយបែរជាមានភារកិច្ចត្រឹមធ្វើកងការពារនារីកូនអ្នកមានម្នាក់? ប្រុសទ្រវ្ងប្រាំហាត់ចំណេះពេញខ្លួនឆ្លងកាត់ការលត់ដំមកមិនចេះតិច សមទេនឹងថយទៅនៅសមរភូមិក្រោយដូចកំសាកញីរបៀបនេះ?

បុរសសក្តិបួនតាំងចិត្តនិយាយច្បាស់ៗទៅកាន់លោកឧត្តមសេនីយ៍ដ៏មានអំណាច៖

«ជម្រាបប្រសាសន៍ទាន! ខ្ញុំរកឃើញតម្រុយមួយក្នុងការបាត់ខ្លួនទាំងបួនករណី!»

ស្ងាត់...

បុរសឋានៈធំមិនតបតែទូរសព្ទក៏មិនបានផ្ដាច់។

ចិត្រាក៏នៅស្ងៀមព្រោះមិនដឹងច្បាស់ថាតើភាគីម្ខាងទៀតចង់បានសម្ដីខ្លួនបន្ត ឬអ្វី?

តែមិនយូរឡើយ បុរសជាមេ សម្លុតត្រឡប់វិញកំបុតៗ៖

«តម្រុយស្អីគេ?»

ដូចផ្លេកបន្ទោរ នាយឆ្លើយតបវិញរឹង៖

«អ្នកបាត់ខ្លួនទាំងបួន មានចំណុចខ្លះ ដូចគ្នាណាស់ទាន!... មិញនេះ ខ្ញុំរកឃើញថា...»

«បានហើយ! មកជួបខ្ញុំនៅស្នងការ!... មកឥឡូវ!»

ខ្សែទូរសព្ទដាច់ តែជាតិ ចិត្រាយល់ពីហេតុផលច្បាស់។

គេដឹងថាបុរសនេះ ប្រុងប្រយ័ត្នមិនព្រមសូម្បីតែនិយាយរឿងអស់នេះតាមប្រព័ន្ធទូរសព្ទ។

ដោយមិនចាំបាច់លុបមុខ គេទាញអាវក្រៅមកគ្របហើយឡើងម៉ូតូធំបញ្ឆេះរោទ៍ចាកចេញ។

**វគ្គ និមិត្តសញ្ញានាគ**

ការិយាល័យប៉ូលិសពេញប្រៀបទៅដោយស្នូរជើងធូន់ៗ។

នៅពាក់កណ្ដាលអគារ ចិត្រាឃើញឯកមាន រត់មកជាមួយនឹងទឹកមុខញញឹមស្ញេញស្ញាញ។

ចិត្រាសង្ស័យ ទោះបីជាឯកមានមិនមានចេតនាឈប់ជើងនិយាយគ្នាក៏ដោយ គេនៅតែឆ្លៀតទាញមិត្ត មកខ្សឹបខ្សៀវ៖

«អ្ហែងសប្បាយចិត្តរឿងអីហ្នឹងអ្ហា?»

ឯកមានក្រឡេកឆ្វេងស្ដាំ មុនពេលលើកសីមីហុចមកបង្ហាញភឿន។

ទឹកមុខចិត្រាឆ្ងល់ម៉ក់ៗ ក្រោមពន្លឺភ្នែកស្រស់ប៉ប្រិមរបស់មិត្ត។ គេសួរខ្លី៖

«អាហ្នឹងស្អី?»

«គេចាត់តាំងអញ ចូលក្រុមITបម្រើឲ្យការងារស៊ើបសង្កេតសំណុំរឿងបាត់ខ្លួនកូនស្រីអ្នកមាន!»

ចិត្រាងក់ក្បាលផ្ងក់ៗ ហើយបញ្ចោះ៖

«ឡូយហើយ!»

នាយដើរហួសទៅ ទាំងអន់ចិត្តនឹងខ្លួនឯង ទុកឲ្យមិត្តនៅតាមសម្លឹងឌីដងពីក្រោយខ្នង។

«មេនៅជាន់ទីពីរ បន្ទប់ពិសោធន៍!»

សំណុំរឿងល្បីរហែកមេឃអ្នកណាមិនចង់ចូលរួម ប៉ូលិសណាម្នាក់មិនចង់មានបទពិសោធន៍ត្រូវបានចារទុកជាមួយរឿងក្ដីដ៏កក្រើកនេះ?

មកដល់ជាន់ទីមួយ សំឡេងប៉ូលិសផ្សេងម្នាក់ស្រែកប្រាប់ចិត្រា៖

«មេឲ្យក្មួយឡើងទៅជួបគាត់!»

«បាទ!»

ចិត្រារត់ឡើងទៅ។

នៅជាន់ទីពីរដែលមានក្លិនបារីឆួល លោកឧត្ដមសេនីយ៍ឈរបែរខ្នងសម្លឹងទៅជើងមេឃក្រហមព្រាលៗនៃការយាងមកជាថ្មីរបស់ទិនករ។

«សូមគោរពទាន!»

គាត់មិនតប តែបែរមកសម្លឹងនាយ។ ចិត្រាឃើញភាពស្មុគស្មាញ នៅក្នុងស្មារតីទទួលខុសត្រូវរបស់ ឧត្ដមសេនីយ៍ប៉ូលិសជើងចាស់ម្នាក់នេះ។ គេដឹងថា អសន្តិសុខសង្គម និងបរាជ័យជាបន្តបន្ទាប់របស់កម្លាំងសមត្ថកិច្ចក្នុងការបំបែកសំណុំរឿងចុងក្រោយដូចជាព្រនង់មួយកំពុងសំពងទៅលើឋានន្តរសក្ដិលើស្មាទាំងសងរបស់គាត់។

បុរសនេះសម្លឹងពិនិត្យពិច័យនាយយើង ពីលើដល់ក្រោមនិងពីក្រោយឡើងលើមុនពេលញែចពន្លត់កន្ទុយបារី។

គេប្រុងហើបមាត់និយាយ តែគាត់លើកដៃរាកាត់។

ប្រអប់ដៃដ៏ធំរបស់ឧត្តមសេនីយ៍លូកមករកកអាវនាយ ហើយទាញរាងកាយនាយសក្តិបួនទៅក្បែរជាមួយពាក្យពោលខ្សឹបៈ

«បើកូនស្រីយើងមានអីកើតឡើង ឯងស្លាប់មិនខាន!»

គាត់និយាយកាចណាស់ ប៉ុន្តែចិត្រាបែរជាមិនខឹង។

ទោះបីទីនេះគ្មានពន្លឺគ្រប់គ្រាន់ ប៉ុន្តែចិត្រាអាចទទួលអារម្មណ៍ដឹងពីសេចក្តីទុក្ខព្រួយលាក់លៀមបង្កប់ក្នុងក្រសែភ្នែកបុរសចំណាស់ម្នាក់នេះ។

សំណួរសំខាន់ពេលនេះសម្រាប់នាយគឺថា ហេតុអ្វីបានជាឧត្តមសេនីយ៍ប្រញាប់ទាញកូនស្រីគាត់ចូលទៅក្នុងការសន្ទនាក្នុងពេលនេះ?

«ប៉ុន្តែទាន! អ្នកបាត់ខ្លួនទាំងបួននាក់មានចំណុចដូចគ្នាមួយបេះបិទ!»

គាត់មិនបានសួរ មិនបានភ្ញាក់ផ្អើល ឬចលាចលអ្វីទាំងអស់ ប៉ុន្តែភ្នែកទាំងគូសម្លឹងផ្តោតមកកូនប៉ូលិសសឹងមើលឲ្យធ្លុះដល់ចិត្តគំនិត។

សំឡេងជាតិ ចិត្រា លាន់ឡើងបន្ថែម ក្នុងកម្លាំងស្រាលៗល្មមឮបានតែពីរនាក់ដែលកំពុងនៅតទល់គ្នាៈ

«ពួកនាងសុទ្ធតែពាក់គ្រឿងអលង្ការរូបនាគ! ដូចគ្នាទាន ចម្លែកណាស់!»

គាត់នៅតែមិនភ្ញាក់ផ្អើល ប៉ុន្តែទម្លាក់ភ្នែកចុះ។ គាត់ដូចជាដឹងរឿងនេះមុននាយប្រាប់ទៅទៀត???

ចិត្រាតាមសម្លឹងប្រតិកម្មរបស់ឧត្តមសេនីយ៍ទាំងចិត្តសង្ស័យ។

ត្រូវហើយ កំហុសធំជាងគេមួយ របស់មនុស្សយើងគឺតែងច្រឡំពេលខ្លះថា ខ្លួនឯងនេះឆ្លាតលើសគេ ពេលនេះ គិតបកមកវិញទើបដឹងថា ពិតជាមានចរិតអន្ទះសា សមមានឋានៈត្រឹមតែជាកូនប៉ូលិសមែន។

លោកនាយម្នាក់នេះនៅការិយាល័យមិនដេកពួន មុខតែសំកុកពិនិត្យឯកសារស្វែងរកដាន សឹងរូងភ្នែកដូចក្តាមទៅហើយ រឿងអីថាគាត់មើលមិនដឹងចំណុចស្រួលៗអស់ទាំងនោះ បើចំណុចទាំងនោះនាយខ្លួនឯងក្រោកពីដេកក្រឡេកមួយឆាច់ក៏ឃើញទៅហើយ។

នាយឈ្មោកមុខទទួលក្តីអាម៉ាស់ ទោះបីគាត់មិនទាន់បានស្តីថាអ្វីសូម្បីតែមួយម៉ាត់ណា។ ផ្ទុយទៅវិញ រៀមច្បងមិនបានបន្ទោសបែរជានិយាយមួយៗក្នុងសភាពទុក្ខព្រួយ៖

«ខ្ញុំឲ្យកូនដាដោះគ្រឿងរូបនាគចេញពីខ្លួនអស់ហើយ! ប៉ុន្តែទោះតម្រុយនេះត្រូវឬខុស វរសេនីយ៍ត្រី ត្រូវតែការពារកូនខ្ញុំឲ្យអស់ពីលទ្ធភាព!»

គេងើបមុខសម្លឹងគាត់។ ជាបុរសខ្លាំងកម្រិតណា គាត់នៅតែជាឪពុកធម្មតាម្នាក់។

នៅពេលដែលរឿងហេតុកើតឡើងផ្ទួនពេក គាត់ទៅជាតក់ស្លុតហើយលែងនឹងនកើត។

ក្នុងគំនិតចិត្រា គេដឹងច្បាស់ថាប្រសិនបើស្ត្រីអភិជនឆ្នាំនាគទាំងអស់សុទ្ធតែជាគោលដៅចាប់ខ្លួន ទោះនាងដោះគ្រឿងអលង្ការទុក តើភាគរយប៉ុនណាដែលថាអាចគេចគ្រោះ។

គេរកនិយាយអ្វីបន្ថែម ប៉ុន្តែគាត់ហាក់មិនចង់ស្តាប់ហើយប្រញាប់និយាយមុន៖

«ខ្ញុំដឹងថា ឯងមិនមែនជាប៉ូលិសធម្មតាទេ! ខ្ញុំផ្ញើជីវិតកូនស្រីតែមួយគត់របស់ខ្ញុំ ក្នុងដៃឯង ឯងគួរយល់ហើយ!»

គាត់ទះស្មានាយតិចៗ ហើយបោះជំហានចេញទៅបន្សល់ភាពស្រឡាំងកាំងឲ្យបុរសក្មេង។

វរសេនីយ៍ត្រីមិនដែលរំភើបអ្វីស្មើនឹងឮពាក្យទាំងនេះ ក្នុងកាលៈទេសៈនេះ ហើយចេញពីមាត់មនុស្សម្នាក់នេះឡើយ។ បានន័យថាគាត់ដឹងតាំងពីដំបូងពីតម្រុយឆ្នាំនាគ?

គាត់គិតថាកូនស្រីគាត់ក៏នឹងក្លាយទៅជាគោលដៅ បានជាមានសភាពពិបាកស្មុគស្មាញយ៉ាងនេះ?

ប៉ុន្តែតើអ្វីទៅ ដែលធ្វើឲ្យគាត់គិតថា ប៉ូលិសតូចតាចម្នាក់នេះ អាចក្លាយជា Superអង្គរក្សបាន?

ទោះបីអ្វីក៏ដោយ ទ្រូងនាយប៉ូលិសកម្រិតវរសេនីយ៍ត្រីចាប់ផ្តើមរីកធំព្រោះមោទនភាព។

គេបែរក្រោយហើយរត់ចុះក្រោម។ គោលដៅសំខាន់គឺឆ្ពោះទៅបំពេញតួនាទី មិនឲ្យអ្នកពឹងពាក់ខកបំណងឡើយ។

នៅចប់តាមផ្លូវ សម្ដីរបស់លោកឧត្តមសេនីយ៍ ជាគ្រឿងកំដរដ៏សក្តិសិទ្ធិ។

«ខ្ញុំផ្ញើជីវិតកូនស្រីតែមួយគត់របស់ខ្ញុំក្នុងដៃឯង ឯងគួរយល់ហើយ!» ម៉្លឹងៗ តើឲ្យនាយញញឹមបិទមាត់ជិតដែរ?

មកដល់ជាន់ខាងក្រោម ប៉ូលិសជាច្រើនដើរចុះឡើងក្នុងលក្ខណៈប្រញិបប្រញាប់។ គេដឹងថាទោះបីពេលនេះ គេអាចហាមឃាត់ករណីជនរងគ្រោះទីប្រាំទៀតបានមែនក៏ដោយ ប៉ូលិសកំពុងស្ថិតក្នុងសភាពដូចទទូរកន្ត្រៀសម្រាប់បន្ទោរបង់ដើរពេញទីក្រុងដូច្នោះដែរ។

«ខ្ញុំកក់ក្ដៅណាស់ទានដែលថ្នាក់ដឹកនាំចាត់តាំងឧត្តមសេនីយ៍ព្រហ្មទណ្ឌឱ្យមកចូលរួមប្រតិបត្តិការបំបែកក្ដីបាត់ខ្លួននេះ!»

ប៉ូលិសសង្ហាម្នាក់មាឌធំខ្ពស់ស្រលាញ់ ឈរបែរខ្នងនិយាយទូរសព្ទ។ ទំនងជាគេនិយាយជាមួយថ្នាក់លើណាម្នាក់ដែលមានឥទ្ធិពល ព្រោះគេនិយាយហើយថែមទាំងអោនលំទោនសូម្បីតែតាមទូរសព្ទ។

សំឡេងគេ  គឺស្នងការមេផ្ទាល់របស់ខ្លួន។

រកធ្វើអ្វីក៏មិនទាន់មិនដឹងគួរគេចឬបន្តនៅ ក៏ស្នងការក្មេង ដាក់ទូរសព្ទចុះងាកមកចំស្រេចទៅហើយ។

«ជាតិចិត្រា!»

គេនិយាយហើយលើកម្រាមចង្អុលមួយសំដៅមក។ កូនប៉ូលិសយើងលើកដៃគោរពទាំងត្រង់ខ្លួនភ្លឹង ធ្វើឱ្យបុរសនោះ ដើរឆ្ពោះតម្រង់មកតែម្ដង។ ជាកូនប៉ូលិសម្នាក់ សូម្បីតែមើលមុខថ្នាក់លើក៏ពុំសមរម្យដែរ ក្នុងចិត្តនាយស័ក្ដិបួន។

ពេលចិត្រារក្សាភ្នែកនឹងថ្កល់រង់ចាំស្ដាប់ Royបញ្ចេញភាពក្រអឺតក្រអោងតាមពន្លឺភ្នែក ទោះបីជាបបូរមាត់នាយរក្សាស្នាមញញឹមដូចគ្មានរឿងអី។

«ក្រែងមានភារកិច្ចជាអ្នកយាមអ្នកនាងអមរាជាអ្វី?»

ទោះបីជាមិនយល់អ្វីច្បាស់លាស់ទាក់ទងនឹងសម្ដីមួយឃ្លាដែលគេទើបនឹងបោះមកនេះ ចិត្រា នៅតែមានអារម្មណ៍ចម្លែកៗថា បុរសនៅចំពោះមុខ គេនេះហាក់កំពុងទម្លាក់តួនាទីលើស្មា ចោល ហើយយកពេលមកឌឺដងខ្លួនដែលជាប៉ូលិសថ្នាក់ទាបម្នាក់។

ធ្វើអ៊ីចឹងដើម្បីអីទៅ?

ស្នងការ Roy ត្បិតតែជាប៉ូលិសវ័យក្មេង តែគេមានសញ្ញាប័ត្រសន្តិសុខសុវត្ថិភាពសង្គមមកពី ចក្រភពអង់គ្លេសហើយសំអាងទៅលើប្រវត្តិ គ្រួសារដ៏មានឋានៈតួនាទីរបស់គេ កុំថាឡើយ យើងជាប៉ូលិសកំប៉ិកកំប៉ុកម្នាក់ ទោះជាឧត្តមសេនីយ៍ប៉ុនលោក ឱត សាម៉ុន ក៏ត្រូវតែទ្រាំនឹង គេម្ដងម្កាលដែរ។

ចាត់ទុកថា គេមកពីបរទេសនិយាយខ្មែរមិនចំន័យ ហើយចាត់ទុកថាយើងស្ដាប់ខុសទៅចុះ។

ចិត្រាលើកដៃដែលដាក់ទន្ទឹមម្ជុក គោរពសាដើម ហើយនិយាយភាសាប៉ូលិសបន្លំចិត្តពិភាល់៖

«សូមគោរពបង!»

កែវភ្នែកលោកនាយ Roy ដែលពិនិត្យ ជាតិ ចិត្រាពីលើដល់ក្រោម មាត់គេញញឹមបែបចំអក ឡកឡឺយ ធ្វើឲ្យអារម្មណ៍អ្នកដែលមានឋានៈតូចទាបជាងកាន់តែគិតមិនយល់ពីមូលហេតុ។

សំឡេងបុរសមានឋានៈលាន់មកសាជាថ្មីលាយសំណើចលឺបលរលាក់ក្នុងបំពង់ក៖

«និយាយអ៊ីចឹង ពូរបស់ឯង! ឧត្តមសេនីយ៍ សេត សេត សេត វិទូ ត្រូវហើយ សេត វិទូ! មាន ជ្រាបតួនាទីថ្មីរបស់ក្មួយឬនៅ?»

បុរសដែលចិត្រាធ្លាប់ទុកជា Idol ជាអ្នកដែលខ្លួនធ្លាប់កោតស្ញប់ស្ញែងមើលតាមកម្មវិធី ទូរទស្សន៍មិនដែលរំលងទុកគេជានិមិត្តរូប ពេលនេះកំពុងធ្វើឲ្យចិត្តវរសេនីយ៍ត្រីចែកមិនដាច់ ថាគួរខឹងឬយ៉ាងណា។

«អ្ហេ! Roy មកហើយល្អណាស់! ចង់ពិភាក្សាគ្នាបន្តិច!»

សំឡេងលោក ឱត សាម៉ុន លាន់មកពីលើជណ្ដើរ ញ៉ាំងឲ្យបុរសស្នងការបញ្ឈប់ការលេងទឹក មុខហើយគ្រប់ខ្លួនឯងជាមួយនឹងកម្រាលមុខខ្លែងក្លាយសុភាពរាបសារ។

«បាទពូ!»

ជាមួយជំហានដែលឪពុកអមរាជាកំពុងឈានចុះមក គេធ្វើជាលើកដៃអង្អែលស្មាប៉ូលិសចិត្រា ហើយ និយាយព្មៗ៖

«ខ្ញុំកំពុងផ្ដាំផ្ញើចិត្រាឲ្យតាមមើលអមរាជាឲ្យល្អ!»

ភាគទី៣

**វគ្គ អង្គរក្សកម្សត់**

មកដល់ផ្ទះ ចិត្រារៀបចំខ្លួនឲ្យបានសមរម្យមុនពេលចេញទៅបំពេញតួនាទីថ្ងៃដំបូង។

គេឱនពាក់ស្រោមជើងផង មាត់និយាយជាមួយម្ដាយប្រញិបប្រញាប់ផង៖

«ម៉ាក់! អាគាត់មកពីអង់គ្លេសហ្នឹងនៅមិននៅ ស្គាល់ឈ្មោះខ្ញុំច្បាស់ទែង ខ្ញុំមិនទាន់ដឹងឫសគល់ផង ស្រាប់តែវាដារ៉ាដៀមដាម ទន្ទឹងទន្ទែងដល់ពូអីឯណាទៀត!!!»

ម្ដាយមិនតប។ ឃើញស្ងាត់ពេក នាយវរសេនីយ៍ត្រីងើបមុខសម្លឹងគាត់។

គាត់ទំនងជាកំពុងពិបាកចិត្តហើយសម្លឹងមកនាយភ្លឹក ភ្លេចទាំងហុចកែវទឹកក្រូចប្រ្របាច់ដែលនៅនឹងថ្កល់លើដៃ។ នាយលូកយកមកក្រេប ហើយទើបនិយាយបន្ធូរចិត្តគាត់វិញ៖

«បានហើយ! ម៉ាក់មិនបាច់គិតទេ! អាគាត់ហ្នឹងបើមិនជួបផ្ទាល់ក៏មិនដឹងថាចរិតយ៉ាប់អ៊ីចឹងដែរ! Idol ក្លាយជាអាយអំពាយហើយពេលនេះ!»

ស្ត្រីដកដង្ហើមធំ ពេលកូនដាក់បង្គុយក្បែរខ្លួនពាក់និងចងខ្សែស្បែកជើង។ គាត់ចាប់ផ្ដើមអង្អែលខ្នងកូនប្រុសតែមួយគត់នេះ ហើយនិយាយមួយៗប្រាប់៖

«កាលពូឯងនៅធ្វើប៉ូលិស គាត់ពូកែហើយល្បីឈ្មោះណាស់! សំណុំរឿងណាដែលធ្លាក់មកដល់ដៃគាត់ គ្មានរឿងមួយណាដែលគាត់បំបែកមិនបាននោះទេ! គាត់លាឈប់ដោយសារអី? មនុស្សយើង ចាស់ថាបើពូកែ ពូកែឲ្យល្មម បើល្បី ល្បីកុំឲ្យលើសមេកោយ! ប្រហែលជាមានគេមិនសប្បាយចិត្តច្រើនហ្នឹងហើយបានវិទូឈប់ពីការងាររាជការ!»

ចិត្រានៅស្ងៀមទាំងមុខស្ងួត។ សង្គមអីក៏ពិបាកម្ល៉េះ? ក្នុងទស្សនៈរបស់វរសេនីយ៍ត្រី។

បើយើងទាប គេដើរជាន់ តែបើយើងលូត ទើសភ្នែកគេ?

នាយគិតតែមិននិយាយចេញ ព្រោះចង់ស្ដាប់វាចាចាស់ទុំបន្ត។

សំឡេងស្ត្រីជាម្ដាយលាន់មកថែមៈ

«សង្ឃឹមថាស្នងការម្នាក់ហ្នឹង មិនដែលមានផលរមាស់អីជាមួយវិទូពីមុនទៅចុះ! ហើយ មួយទៀត បានទៅផ្ទះឧត្ដមសេនីយ៍ បានលោកទុកចិត្ត ក៏គិតពីខំធ្វើការខ្លួនតាមតួនាទីទៅណាកូន! មនុស្សឋានៈលើយើង និយាយស្ដីលើបន្តិច កុំប្រកាន់វែងឆ្ងាយ ទុកថាស្ដាប់មិនឮទៅចុះ!?»

ចេញពីម្ដាយមក ចិត្រារក្សាទុកចម្ងល់ពីរ។ ទីមួយ តើដែលនាយ Roy យកឈ្មោះឪពុកមាខ្លួនមកនិយាយលេងសើចនេះ គេមានមូលហេតុយ៉ាងណានៅពីក្រោយ? ទីពីរ តាមវ័យរបស់គេ តើគេសមថាមកច្រណែននិងឧត្ដមសេនីយ៍ ចូលនិវត្តម្នាក់ដែរឬយ៉ាងណា?

«អង្គរក្សរបស់អ្នកនាងតូច?»

អ្នកបើកទ្វារសួរដោយញញឹម ចំណែកប៉ូលិសយើង រុញម៉ូតូចូលតានទ្វារចំហៀងតូចនៃគេហដ្ឋានធំចង្គ្រឹង។

ផ្ទះឧត្ដមសេនីយ៍ឱត សាម៉ុន ពិតជាធំជាងការគិតរបស់នាយ។ អ្នកយាមបាត់ទៅណាអស់?

គេគិតប្រើយើងម្នាក់ឯងហ្នឹងឲ្យមករក្សាសុវត្ថិភាពផ្ទះនេះទាំងមូល?

«ម៉ោណេះៗ ចូលមកណេះ ម៉ាឡា!»

សំឡេងហៅពីជាន់ខាងលើធ្វើឲ្យអ្នកបើកទ្វារម្នាក់នេះប្រញិបប្រញាប់ឡើងទៅដោយមិនភ្លេចងាកមកផ្ដាំផ្ញើចិត្រាៈ

«បិទទ្វារឲ្យស្រួលផងក្មួយ! មួយរយៈនេះភ្នំពេញយើងដូចជាមានរឿងមិនសូវស្រួលសោះ បាត់ខ្លួនកូនអ្នកធំៗជាប់ៗគ្នា!»

«លឿនមកម៉ាឡា!»

ស្ត្រីដែលស្លៀកពាក់សមជាមេផ្ទះនេះរលះរលាំងចាកចេញទៅ ទុកឲ្យកូនប៉ូលិសនៅបិទទ្វារ ហើយអូសម៉ូតូចូលខ្លួនឯង។

តាមពិតផ្ទះនេះទំនងជាមានព្រឹត្តិការណ៍អ្វីព្រោះចាប់អារម្មណ៍ឃើញថានៅសួនខាងក្រោយពួកអ្នកបម្រើស្រីរត់ចុះឡើងញាប់ដៃជើង។

ឡានទំនើបទាំងជួរៗបង្ហាញថាផ្ទះនេះកំពុងមានភ្ញៀវពន្លឺ ទោះបីជាឧត្តមសេនីយ៍ ឱត សាម៉ុន មិននៅផ្ទះក៏ដោយ។

«ទុកម៉ូតូត្រង់ហ្នឹងចុះលោកសក្តិបួន!»

ប៉ូលិសកម្សត់ងើបមុខសម្លឹងម្ចាស់ដែលជាមនុស្សប្រុសចំណាស់។

គាត់កំពុងជូតសំអាតរថយន្តមួយថ្មីទែង ហើយញញឹមពព្រាយស្វាគមន៍នាយ។

ចិត្រានៅមិនទាន់រៀបឫកឲ្យសមរម្យនឹងអាលរាក់ទាក់គាត់វិញផង បុរសនេះណែនាំខ្លួនគាត់ជាស្រេចទៅហើយ៖

«ពូហឿន!!! នេះពូហឿន ជាអ្នកបើកបរជូនអ្នកនាងតូចអមរាជា!»

ឃើញគាត់រួសរាយចង្អុលទ្រូងខ្លួនឯងប្រាប់ឈ្មោះក្តែងៗ ចិត្រាធូរចិត្តពីក្តីសៅហ្មងដែលទើបនឹងជួបកាលពីព្រឹកនៅឯស្នងការ។

គេមិនទាន់ហាមាត់និយាយអ្វីផង បុរសតែកុងនិយាយបន្ថែមស្រេចទៅហើយ៖

«រីករាយណាស់បានលោកសក្តិបួនមក! ពូហឿនអស់កង្វល់ល្មម!»

«កុំហៅខ្ញុំអ៊ីចឹងអាក្រក់ស្តាប់ណាស់ពូ! ហៅចិត្រា ឬចិត្រក៏បាន!»

បុរសចំណាស់ញញឹមសម្លឹងនាយប៉ូលិសពីក្បាលដល់ចុងជើង។ គាត់គ្រវីក្បាលម្តងហើយម្តងទៀត តែមាត់នៅតែញញឹមហើយស្រដីរអុះៗ៖

«ដូចណាស់! ដូចមែនទែន!»

គាត់ពុំត្រឹមតែរួសរាយ ថែមទាំងមានសម្តីចម្លែកឡើងៗ ដល់ថ្នាក់នាយរកពាក្យហើយតបមិនបាន ត្រឹមចំហមាត់ញញឹមសម្លឹងមើលដោយស្ងាត់ស្ងៀម រង់ចាំថាគាត់នៅមានអីទៀត?

បុរសចំណាស់ពិតជាមិនឈប់មែន គាត់និយាយបន្ថែមរដឹក៖

«ដឹងដូចអ្នកណាអត់?»

«អ្នកណាទៅពូ?»

ចិត្រាសួរខ្លីធ្វើឲ្យតែកុងសើចខឹកៗ

«ឧត្តមសេនីយ៍សេតវិទូ!»

ចិត្រាភាំង។ អ្វីដែលវិលខ្វាល់មកក្នុងអារម្មណ៍កំលោះប៉ូលិសនៅពេលនេះ គឺថាហេតុអីលោកមាមានមនុស្សស្គាល់ច្រើនយ៉ាងនេះ?

ក្តីស្រពោនមួយលេចចេញភ្លាមក្នុងអារម្មណ៍វរសេនីយ៍ត្រី សម្តីលែបខាយរបស់ស្នងការ Roy លាន់មកវិញក្នុងការចងចាំ «ចុះពូឯងដឹងអត់ ថាក្មួយគាត់អស់កាលីបត្រឹមដើរតាមយួរកាបូបឲ្យស្រីៗប៉ុណ្ណឹង?»។

ចិត្រាខំបន្លប់ទុក្ខព្រួយជាមួយប្រយោគស្រាលៗ៖

«ដូចអីពូ! តាំងពីកើតមក គ្មានឃើញអ្នកណាសរសើរថាខ្ញុំមានរូបរាងដូចពូខ្ញុំសោះហ្នឹង! មានតែពូម្នាក់!»

បុរសសើចខឹកៗហើយវាចាតប៖

«ពូមិននិយាយរឿងរូបរាងទេ គឺសកម្មភាព អាកប្បកិរិយា!»

ចិត្រានៅស្ងាត់ស្ងៀមវិញ ហើយប្រឹងត្រិះរិះសម្តីបុរសចំណាស់។ ជួបគ្នាភ្លាមគាត់សំអាងអីមកវាយតម្លៃអាកប្បកិរិយាខ្លួនយកទៅប្រដូចនឹងពូខ្លួនលឿនដល់ម្លឹង?

មិនទាន់បានតបថាយ៉ាងណាផង សំឡេងថ្មីលាន់មកពីប្រភពផ្សេង៖

«ឧត្តមសេនីយ៍វិទូសុខសប្បាយទេ?»

វរសេនីយ៍ត្រីបែរក្រោយយឺតៗទៅរកប្រភពសំឡេងដែលជាមនុស្សស្រី។

លោកជំទាវរបស់ឧត្តមសេនីយ៍ ឱត សាម៉ុន ពិតជាស្រស់ស្អាតថ្លៃថ្នូរទៅតាមវ័យរបស់គាត់ ចុះទម្រាំតើអ្នកនាងអមរាដា ស្រស់ស្រទន់កម្រិតណាទៀត?

ចិត្តកំលោះបាចសាចទៅតាមសំណួរក្នុងអារម្មណ៍ដែលរាយប៉ាយ ហើយស្នាមញញឹមរបស់ស្ត្រីម្ចាស់ផ្ទះក៏កំពុងផ្តល់មកឲ្យនាយនូវកិច្ចស្វាគមន៍កក់ក្តៅ។

បុរសចំណាស់ប្រញាប់តឿន៖

«ជម្រាបសួរលោកជំទាវទៅ!»

នាយប៉ូលិសឱនកាយស្របពេលស្ត្រីអភិជនបន្ថែមសម្ដី៖

«ច្រើនឆ្នាំហើយ លោកពូបានកូនចៅប៉ុន្មានហើយ?»

ចិត្រាងើបមុខហើយពោលតបដោយប្រយ័ត្នប្រយែង៖

«គាត់និងអ្នកមីងនិស្ស័យបានកូនប្រុសម្នាក់អាយុ៤ឆ្នាំ!»

ជំទាវងក់ក្បាលផ្ងក់ៗ ហើយតប៖

«ខ្ញុំបានចូលរួម មង្គលការពួកគេដែរ! គិតទៅបួនប្រាំឆ្នាំហើយមែន! មោះ ចូលមកក្មួយ!»

គាត់បង្ហាញខ្លួនជូននាយចូលទៅក្នុងគេហដ្ឋានធំទូលាយ ជាអាកប្បកិរិយាដ៏កម្រនៃបណ្ដាស្ត្រីភរិយាអ្នកមានសក្តិយស។

«ពូក្មួយពីមុនឧស្សាហ៍មកបាយនៅទីនេះ ពិភាក្សាការងារជាមួយស្វាមីខ្ញុំ! គេជាមនុស្សពូកែ មធ្យ័តហើយចរិតល្អ!»

មិនដឹងជាហេតុអ្វីឲ្យតែអ្នកណារំឭកពីលោកពូដ៏មានវីរភាពរបស់គេ នាយប៉ូលិសមានអារម្មណ៍ថារងសម្ពាធ។

នៅកណ្ដាលគេហដ្ឋានដ៏ស្កឹមស្កៃរុងរឿង នាយមើលមិនឃើញអ្នកនាងតូចដែលខ្លួនត្រូវការពារនោះនៅឡើយទេ។ ចិត្តមួយបារម្ភថានាងអាចនឹងមានចរិតទំនើងកាចឆ្នាស ដូចធ្លាប់ឃើញក្នុងកុន ចិត្តមួយទៀតមិនដឹងថា តើជាអង្គរក្សដ៏បន្ទាន់និងគ្មានជំនាញបែបនេះ ធ្វើម៉េចចេះវិធីការពារនិងផ្គាប់ចិត្តកូនស្រីលោកឧត្តមសេនីយ៍ឲ្យបានត្រូវក្បួននោះ?

«កូនដាថ្ងៃនេះមិនចេញទៅណាទេ!»

លោកជំទាវមានប្រសាសន៍ហាក់យល់ចិត្តនាយដែលកំពុងរំពៃរកម្ចាស់ស្រី។ ប៉ូលិសយើងញញឹមហាក់ធូរចិត្ត ព្រោះថ្ងៃដំបូងនៃជីវិតជាអង្គរក្សគឺការពារអ្នកនាងតូចនៅក្នុងមហាកំផែងនេះ តើមានសត្រូវឯណាហ៊ានចូលមកលុកលុយដល់ទីនេះទៅ។

គេមិនទាន់និយាយតបវិញផង លោកជំទាវវ៉ាចាប់ផ្ដើមៈ

«ថ្ងៃនេះផ្ទះយើងមានភ្ញៀវ តែលោកប៉ារបស់កូនដារវល់នៅនឹងស្នងការតាំងពីយប់ ក្មួយជួយរៀបចំក្នុងក្រៅជាមួយអ្នកម៉ាឡានិងបងហឿនចុះណា!»

ទីបំផុតក៏ទទួលអារម្មណ៍ថាបានធ្លាក់ខ្លួនជាអ្នកបម្រើគេពេញលក្ខណៈមែនហើយ។

នេះសមនឹងឲ្យអាគាត់ Roy និយាយដៀមដាមគ្មានខុសអីបន្តិច!

គេគ្មានជម្រើសអ្វីក្រៅតែពីឆ្លើយបាទ ទាំងលាក់ចិត្តស្រពោនឲ្យនៅសោកសៅត្រឹមតែក្នុងទ្រូង។

«ពូ នៅទីនេះអត់មានអ្នកណាក្រៅពីពូនិងមីងម៉ាឡាទេ?»

«មានប៉ូលិសបីបួននាក់មកយាមតែញឹក ជាពិសេសសៅរ៍ អាទិត្យ ពេលល្ងាចៗ សម្រាកការងារ ពួកគេមកជួយការងារនៅនេះដែរ! ខាងអ្នកមាឡាគេមានដៃកាំបិត មានក្មេងស្រីៗបីបួននាក់ទៀតនៅផ្ទះបាយ!»

ពូហឿនបានមកនាំគេចេញទៅឲ្យគិតគូរពីចំណតឡានដែលបន្តិចទៀតត្រូវទទួលឡានភ្ញៀវ។

រយៈពេលនេះដ៏គួរឲ្យអាណិតខ្លួននេះ គេនឹកគិតទៅដល់លោកពូដែលជានិមិត្តរូបដ៏ជោគជ័យរបស់ខ្លួន។

«ឱលោកពូខ្ញុំ! លោកពូកើតមកខ្លាំងពូកែ មានសមត្ថភាពនិងស្នាដៃឲ្យអ្នកផងកោតក្រែង ពូជួយគិតក្មួយម្នាក់នេះផង ខំហាត់រៀនមិនហ៊ានប្រហែស ក្រិនអស់ដៃជើង ស្ពឹកអស់ខួរក្បាលមើលឯកសារសឹងមីញ៉ូបអស់ភ្នែក ចុងក្រោយមកក្លាយជាប៉ូលិសអង្គរក្សយ៉ាងកម្សត់ ធ្វើតួនាទីដូចអ្នកបម្រើគេ តើសមដែរទេ?»

ទោះបីកំពុងខូចចិត្ត តែគេត្រូវរកអ្វីម្យ៉ាងមកបន្លប់ទុក្ខព្រួយរបស់ខ្លួន។

ប្រធានបទដែលគួរលើកមកនិយាយល្អបំផុតក្នុងពេលនេះគឺ រំឭករឿងល្អៗរបស់ពូខ្លួនក្រែងអាចមាន មោទនភាព គេចផុតក្ដីទុក្ខព្រួយកង្វល់បាន?

«កាលមុន ពូខ្ញុំឧស្សាហ៍ចេញចូលទីនេះ?»

ពូហឿនញញឹមហាក់បីដូចជាកំពុងរីករាយនឹងរំឭកៈ

«ត្រូវហើយ! មានម្តង គាត់ដើរមកជិតខ្ញុំ ហើយសួរខ្ញុំថា ចង់រៀនស៊ើបក្តី? ខ្ញុំថាចង់! គាត់ក៏បន្តថាបងឯងឆ្លើយសំណួរខ្ញុំមួយឲ្យរួចសិនទៅ គាត់ចាប់ផ្តើមសួរខ្ញុំថា បុរសម្នាក់ស្លៀកពាក់ខ្មៅក្រឹបកំពុងដើរម្នាក់ឯងតាមផ្លូវដែលគ្មានពន្លឺភ្លើងមួយសរសៃ រំពេចនោះមានឡានមួយពណ៌ខ្មៅក្រឹបហើយខូចហ្វាភ្លើងអស់ទៀត ឡានកំពុងបោលល្បឿនស្លេវ តែពេលមកដល់ជិតបុរសនោះ ក៏បន្ថយល្បឿនហើយគេចចេញសំណួរថា  តើរថយន្តនោះម៉េចដឹងថា មានបុរសម្នាក់នៅត្រង់នុះ? »

«ព្រោះនោះជាពេលថ្ងៃ!»

ចិត្រាឆ្លើយតាមធម្មតាធ្វើឲ្យបុរសតែភ័ន្តភាំងមុនពេលញញឹមសួរៈ

«ធ្លាប់ដឹងចម្លើយហ្អី?»

ចិត្រាញញឹមតបៈ

«អត់ផង! សំណួរធម្មតាៗ!»

«អត់ទេក្មួយប៉ូលិស! មានធម្មតាឯណាទេ ពូកាលហ្នឹងរកនឹកមួយថ្ងៃនៅតែនឹកមិនឃើញ! បើមិនបានដឹងមុនទេ បានន័យថាក្មួយឆ្លាតមិនចាញ់ឧត្តមសេនីយ៍រិទ្ធទេ តែក្នុងមួយប៉ប្រិចភ្នែកអាចឆ្លើយបាន!»

ចិត្រាសើចតបរីករាយនឹងពាក្យសរសើរ។ ម្តងណោះនាយទទួលស្គាល់ថានិយាយរំឭកពីលោកមាដ៏មហិមាម្នាក់នោះក៏មិនប្រាកថា រងសម្ពាធទាំងស្រុងដែរ។